# សេចក្ដីពន្យល់អំពីអង្គហេតុចំបងដែលជាធាតុផ្សំ

## ~ករណីស្ដីពីការលែងលះ, ការចែកមត៌ក~

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់
សាស្ត្រាចារ្យ Mr. Kai Yuji

# រឿងក្តីស្តីពីការលែងលះ

<ចូរសាកល្បងរៀបចំរឿងក្តី>

1. ស្តីពីសាលក្រមដែលទាមទារ
2. ស្តីពីការទាមទារ
3. ស្តីពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ
4. ស្តីពីការទទួលស្គាល់ ឬមិនទទួលស្គាល់, ស្តីពីការតវ៉ារបស់ចុងចម្លើយ
5. ស្តីពីការកំណត់អ្នកមានអំណាចមេបា
6. ស្តីពីសោហ៊ុយសម្រាប់គ្រប់គ្រងថែទាំកូន
7. ស្តីពីការចែកទ្រព្យសម្បត្តិ

# 1. សាលក្រមដែលទាមទារ

- សាលក្រមដែលទាមទារនៃរឿងក្តីនេះ គឺ ៖

1. ដើមចោទនិងចុងចម្លើយលែងលះគ្នា។
2. កំណត់ថា ដើមចោទជាអ្នកមានអំណាចមេបាទៅលើកូនស្រីច្បងឈ្មោះ A (កើតថ្ងៃទី1 មិថុនា 2005) និងកូនស្រីទី២ឈ្មោះ B (កើតថ្ងៃទី20 មករា 2012) ដែលទាំងពីរជាកូនរវាងដើមចោទនិងចុងចម្លើយ។
3. ចុងចម្លើយត្រូវបង់សោហ៊ុយសម្រាប់គ្រប់គ្រងថែទាំកូនស្រីច្បង A និងកូនស្រីទី២ B ក្នុងមួយខែ●●ដុល្លារសម្រាប់ម្នាក់ រាល់ចុងខែ ដោយគិតពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ រហូតដល់កូនម្នាក់ៗក្លាយជានីតិជន ទៅឱ្យដើមចោទ។
4. បែងចែកដីនិងអាគារដែលចុះក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធស្តីពីទ្រព្យសម្បត្តិរួម និងប្រាក់បញ្ញើក្នុងធនាគារ។

# 1. សាលក្រមដែលទាមទារ

- ស្ដីពីការចែកទ្រព្យសម្បត្តិ បើសិនជាសរសេរលំអិតទៅមានដូចតទៅ ៖

4. បែងចែកដីនិងអាគារដែលចុះក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធស្ដីពីទ្រព្យសម្បត្តិរួម និងប្រាក់បញ្ញើក្នុងធនាគារ។

(1) ចែកដីនិងអាគារដែលមានចុះក្នុងបញ្ជីសារពើភ័ណ្ឌឧបសម្ព័ន្ធស្ដីពីទ្រព្យសម្បត្តិរួម គឺជាកម្មសិទ្ធិរបស់ចុងចម្លើយ។

(2) ដើមចោទត្រូវធ្វើនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិ នូវចំណែករបស់ខ្លួនក្នុងសហកម្មសិទ្ធិលើដីនិងអាគារខាងលើនេះ ទៅឱ្យចុងចម្លើយ ដោយមូលហេតុបែងចែកទ្រព្យសម្បត្តិ។

(3) ចុងចម្លើយត្រូវបង់ប្រាក់ 10,000ដុល្លារទៅឱ្យដើមចោទ។

# រឿងក្តីស្តីពីការលែងលះ

<ចូរសាកល្បងរៀបចំរឿងក្តី>

1. ស្តីពីសាលក្រមដែលទាមទារ
2. ស្តីពីការទាមទារ
3. ស្តីពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ
4. ស្តីពីការទទួលស្គាល់ ឬមិនទទួលស្គាល់, ស្តីពីការតវ៉ារបស់ចុងចម្លើយ
5. ស្តីពីការកំណត់អ្នកមានអំណាចមេបា
6. ស្តីពីសោហ៊ុយសម្រាប់គ្រប់គ្រងថែទាំកូន
7. ស្តីពីការចែកទ្រព្យសម្បត្តិ

# 2. ការទាមទារ

- ដើមចោទបានទាមទារ៤ចំណុច ?

1. “ទាមទារការលែងលះ។”
   - សិទ្ធិទាមទារការលែងលះ(មាត្រា978)
2. “ទាមទារការកំណត់អំណាចមេបា។”
   - មិនមែនជាការទាមទារទេ គឺជាការសម្រេចរបស់តុលាការក្នុងករណីលែងលះ(មាត្រា1037 កថាខ័ណ្ឌទី3)
3. “ត្រូវបង់សោហ៊ុយសម្រាប់គ្រប់គ្រងថែរក្សាកូន។”
   - សិទ្ធិទាមទារឱ្យបង់សោហ៊ុយសម្រាប់គ្រប់គ្រងថែរក្សាកូន(មាត្រា1040)
4. “ទាមទារឱ្យចែកទ្រព្យសម្បត្តិ។”
   - សិទ្ធិទាមទារឱ្យចែកទ្រព្យសម្បត្តិ(មាត្រា980)

※2,3,4 គឺជាការដាក់ពាក្យសុំអំពីការចាត់ចែងបន្ទាប់បន្សំ(ច្បាប់ស្តីពីបណ្តឹងដែលទាក់ទងនឹងឋានៈបុគ្គល មាត្រា22)

# រឿងក្ដីស្ដីពីការលែងលះ

<ចូរសាកល្បងរៀបចំរឿងក្ដី>

1. ស្ដីពីសាលក្រមដែលទាមទារ
2. ស្ដីពីការទាមទារ
3. ស្ដីពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ
4. ស្ដីពីការទទួលស្គាល់ ឬមិនទទួលស្គាល់, ស្ដីពីការតវ៉ារបស់ចុងចម្លើយ
5. ស្ដីពីការកំណត់អ្នកមានអំណាចមេបា
6. ស្ដីពីសោហ៊ុយសម្រាប់គ្រប់គ្រងថែទាំកូន
7. ស្ដីពីការចែកទ្រព្យសម្បត្តិ

# 3. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

- ការទាមទារនូវការលែងលះ :
- ក្រមរដ្ឋប្បវេណី មាត្រា978 កថាខ័ណ្ឌទី1 ចំណុច ង
  - ទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយ គ្មានសង្ឃឹមថានឹងអាចបដិទានឡើងវិញបាន
  - នេះមិនមែនជាអង្គហេតុទេ  គឺជាការវាយតម្លៃដោយផ្អែកលើអង្គហេតុ។
  - អង្គហេតុជាក់លាក់ដែលជាមូលដ្ឋាននៃការវាយតម្លៃនេះ គឺជាអង្គហេតុដែលជាមូលហេតុនៃការទាមទារ។
  - ទោះជាមានការទទួលស្គាល់នូវអង្គហេតុដែលជាមូលហេតុនៃការវាយតម្លៃនេះក៏ដោយ  តែអង្គហេតុដែលជាមូលហេតុបញ្ជាក់ថា អាពាហ៍ពិពាហ៍មិនទាន់បែងបាក់ គឺជាអង្គហេតុតវ៉ា។

# 3. អង្គហេតុដែលជាមូលហេតុនៃការទាមទារ

- អង្គហេតុដែលសំអាងការបែកបាក់នៃអាពាហ៍ពិពាហ៍

A) អំពើហិង្សា, ពាក្យសំដីហិង្សា
B) ទាមទារប្រាក់កាសគ្មានប្រណី
C) ឥរិយាបថមិនសហការគ្នាក្នុងជីវភាពរស់នៅក្នុងផ្ទះ
D) ការរស់នៅបែកគ្នា

# រឿងក្តីស្តីពីការលែងលះ

<ចូរសាកល្បងរៀបចំរឿងក្តី>

1. ស្តីពីសាលក្រមដែលទាមទារ
2. ស្តីពីការទាមទារ
3. ស្តីពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ
4. ស្តីពីការទទួលស្គាល់ ឬមិនទទួលស្គាល់, ស្តីពីការតវ៉ារបស់ចុងចម្លើយ
5. ស្តីពីការកំណត់អ្នកមានអំណាចមេបា
6. ស្តីពីសោហ៊ុយសម្រាប់គ្រប់គ្រងថែទាំកូន
7. ស្តីពីការចែកទ្រព្យសម្បត្តិ

# 4. ការទទួលស្គាល់ឬមិនទទួលស្គាល់(ការទាមទារនូវការលែងលះ)

- មូលហេតុនៃការទាមទារ : អង្គហេតុសំអាងនូវការបែកបាក់នៃអាពាហ៍ពិពាហ៍

A) អំពើហិង្សា, ពាក្យសំដីហិង្សា
→បដិសេធ

B) ការទាមទារប្រាក់កាសគ្មានប្រណី
→បដិសេធ

C) ឥរិយាបថមិនសហការគ្នាក្នុងជីវភាពរស់នៅក្នុងផ្ទះ
→បដិសេធ

D) ការរស់នៅបែកគ្នា
→គ្មានវិវាទ

# 4. ការតវ៉ា(ការទាមទារនូវការលែងលះ)

- ការតវ៉ា : អង្គហេតុដែលជាឧបស័គនៃការបែកបាក់នៃអាពាហ៍ពិពាហ៍

A) ការដើរលែងជាមួយគ្រួសារ ជាដើម

# រឿងក្តីស្តីពីការលែងលះ

<ចូរសាកល្បងរៀបចំរឿងក្តី>

1. ស្តីពីសាលក្រមដែលទាមទារ
2. ស្តីពីការទាមទារ
3. ស្តីពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ
4. ស្តីពីការទទួលស្គាល់ ឬមិនទទួលស្គាល់, ស្តីពីការតវ៉ារបស់ចុងចម្លើយ
5. ស្តីពីការកំណត់អ្នកមានអំណាចមេបា
6. ស្តីពីសោហ៊ុយសម្រាប់គ្រប់គ្រងថែទាំកូន
7. ស្តីពីការចែកទ្រព្យសម្បត្តិ

# 5. ការកំណត់អ្នកមានអំណាចមេបា

- ស្ដីពីការកំណត់អ្នកមានអំណាចមេបា តើត្រូវសរសេរអ្វីខ្លះនៅក្នុងពាក្យបណ្ដឹង និងឯកសារចម្លើយ ?
- ស្ដីពីការកំណត់អ្នកមានអំណាចមេបា សូមពិចារណាថា តើតុលាការត្រូវធ្វើការវិនិច្ឆ័យដោយផ្អែកលើសភាពការណ៍អ្វីខ្លះ ?
- តុលាការអាចយកអង្គហេតុដែលមិនបានអះអាង មកពិចារណាបាន(ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ, ច្បាប់ស្ដីពីនីតិវិធីនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា14)។
  - ក៏ប៉ុន្តែ ភាគីគប្បីធ្វើការអះអាង ជាការល្អ។

# 5. ការកំណត់អ្នកមានអំណាចមេបា

- “ត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាដល់ផលប្រយោជន៍របស់កូន” (មាត្រា1037)

A) ស្ថានភាពនៃការគ្រប់គ្រងថែរក្សារបស់ឪពុកម្តាយដែលរស់នៅជាមួយគ្នា

B) ឥរិយាបថនៃការគ្រប់គ្រងថែរក្សារបស់ឪពុកម្តាយដែលរស់នៅបែកគ្នា

C) ឆន្ទៈ និង ទឹកចិត្តរបស់កូន(ច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា22 កថាខ័ណ្ឌទី4)

D) សភាពការណ៍រហូតដល់រស់នៅបែកគ្នា(តើមានការនាំទៅខុសច្បាប់ឬទេ ?)

# រឿងក្តីស្តីពីការលែងលះ

<ចូរសាកល្បងរៀបចំរឿងក្តី>

1. ស្តីពីសាលក្រមដែលទាមទារ
2. ស្តីពីការទាមទារ
3. ស្តីពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ
4. ស្តីពីការទទួលស្គាល់ ឬមិនទទួលស្គាល់, ស្តីពីការតវ៉ារបស់ចុងចម្លើយ
5. ស្តីពីការកំណត់អ្នកមានអំណាចមេបា
6. ស្តីពីសោហ៊ុយសម្រាប់គ្រប់គ្រងថៃទាំកូន
7. ស្តីពីការចែកទ្រព្យសម្បត្តិ

# 6. សោហ៊ុយសម្រាប់គ្រប់គ្រងថៃទាំ

- “ស្ដីពីបន្ទុកនៃសោហ៊ុយចាំបាច់សម្រាប់ គ្រប់គ្រងថៃទាំកូន ត្រូវកំណត់ដោយគិតពិចារណាទៅលើស្ថានភាពនៃជីវភាព និង ស្ថានភាពសេដ្ឋកិច្ច របស់ឪពុកម្ដាយ” (មាត្រា1040 កថាខ័ណ្ឌទី6)

A) ស្ថានភាពនៃជីវភាព និង ស្ថានភាពសេដ្ឋកិច្ចរបស់ឪពុកម្ដាយ
   - សមាជិកគ្រួសារ
   - ស្ថានភាពនៃជីវភាពរស់នៅ
   - ចំណូលចំណាយ
   - អាយុរបស់កូន

# រឿងក្ដីស្ដីពីការលែងលះ

<ចូរសាកល្បងរៀបចំរឿងក្ដី>

1. ស្ដីពីសាលក្រមដែលទាមទារ
2. ស្ដីពីការទាមទារ
3. ស្ដីពីអង្គហេតុដែលជាមូលហេតុនៃការទាមទារ
4. ស្ដីពីការទទួលស្គាល់ ឬមិនទទួលស្គាល់, ស្ដីពីការតវ៉ារបស់ចុងចម្លើយ
5. ស្ដីពីការកំណត់អ្នកមានអំណាចមេបា
6. ស្ដីពីសោហ៊ុយសម្រាប់គ្រប់គ្រងថែទាំកូន
7. ស្ដីពីការចែកទ្រព្យសម្បត្តិ

# 7. ការចែកទ្រព្យសម្បត្តិ

- “បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែកសហព័ទ្ធនីមួយៗ មានសិទ្ធិទទួលយក ១ ភាគ ២ នៃទ្រព្យសម្បត្តិរួម” (មាត្រា980 កថាខ័ណ្ឌទី2 ចំណុច ខ.)
- វិធីគណនា

A) បូកសរុបនូវទ្រព្យសម្បត្តិរួម(នៅជប៉ុន គេយកពេលដែលចេញទៅរស់នៅបែកគ្នាមកធ្វើជាមូលដ្ឋាន)

B) គណនាទឹកប្រាក់1/2 នៃចំណុចA

C) ត្រូវសម្រួបយ៉ាងណាឱ្យទ្រព្យសម្បត្តិរបស់ប្តីនិងប្រពន្ធមានស្មើនឹងទឹកប្រាក់គណនាក្នុងចំណុច B

# 7. ការចែកទ្រព្យសម្បត្តិ

- សរុបនៃទ្រព្យសម្បត្តិរបស់ X 55000ដុល្លារ
  - ½ នៃអាគារនិងដី 35000ដុល្លារ
  - ប្រាក់បញ្ញើ 20000ដុល្លារ
- សរុបនៃទ្រព្យសម្បត្តិរបស់ Y 5000ដុល្លារ
  - ½ នៃអាគារនិងដី 35000ដុល្លារ
  - បំណុល -40000ដុល្លារ
  - ប្រាក់បញ្ញើ 10000ដុល្លារ
- សរុបនៃទ្រព្យសម្បត្តិរួម 60000ដុល្លារ

# 7. ការចែកទ្រព្យសម្បត្តិ

- វិធីគណនា
  - A) គណនាទ្រព្យសម្បត្តិរួម 60000ដុល្លារ
  - B) A÷2=30000ដុល្លារ
  - C) ត្រូវសម្របយ៉ាងណាឱ្យទ្រព្យសម្បត្តិរបស់ប្ដីនិងប្រពន្ធមានស្មើនឹងទឹកប្រាក់គណនាក្នុងចំណុច B

ចំណែកនៃអាគារនិងដី 35000ដុល្លារ

X 55000ដុល្លារ → Y5000ដុល្លារ

X 20000ដុល្លារ ← Y 40000ដុល្លារ

បង់ប្រាក់ 10000ដុល្លារ

X 30000ដុល្លារ Y 30000ដុល្លារ

# ទាមទារលែងលះ

អង្គហេតុនៃ
អាពាហ៍ពិពាហ៍

អង្គហេតុដែលសំអាង
នូវការបែកបាក់នៃ
អាពាហ៍ពិពាហ៍

អង្គហេតុដែលជាឧបស័គនៃ
ការបែកបាក់នៃអាពាហ៍ពិពាហ៍

# រឿងក្ដីស្ដីពីការចែកមត៌ក

< ចូរសាកល្បងរៀបចំរឿងក្ដី>

1. អ្វីទៅ ការចែកមត៌ក ?
2. ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំមានអ្វីខ្លះ ?
3. អ្វីទៅ ដីការសម្រេចដែលទាមទារ ?
4. តើអង្គហេតុដែលជាមូលហេតុ មានអ្វីខ្លះ ?
5. ចំណុចដែលត្រូវសរសេរក្រៅពីនេះ មានអ្វីខ្លះ ?
6. សង្ខេប

# 1. ការចែកមត៌ក

- អ្វីទៅ មត៌ក ?
  - ការចាប់ផ្តើមធ្វើសន្តតិកម្ម(មាត្រា1145)
  - ការទទួលបន្តនូវមត៌ក(មាត្រា1147)
  - ការទទួលបន្តតាមរយៈការចែក(មាត្រា1148កថាខ័ណ្ឌទី1 វាក្យខ័ណ្ឌទី1)
    - របស់អ្វីដែលអាចបែងចែកបាន ដូចជា សិទ្ធិលើបំណុលជាប្រាក់ ជាដើម ត្រូវធ្វើការបែងចែក ហើយទទួលបន្ត។
    - Ex) សិទ្ធិលើបំណុលដែលជាប្រាក់បញ្ញើ
  - មត៌កអវិភាគ(មាត្រា1148 កថាខ័ណ្ឌទី1 វាក្យខ័ណ្ឌទី2, កថាខ័ណ្ឌទី2)
    - Ex) អចលនវត្ថុ, សាច់ប្រាក់

# 1. ការចែកមត៌ក

- អ្វីទៅ មត៌កអវិភាគ ?
  - ស្តីពីសហកម្មសិទ្ធិ មានចែងក្នុងក្រមរដ្ឋប្បវេណី ពីមាត្រា202 ទៅ
  - ក្នុងករណីដែលមានវត្ថុអវិភាគ ក្រៅពីមត៌កអវិភាគ គេអាចទាមទារឱ្យចែកវត្ថុអវិភាគបាន (មាត្រា211)។
  - ក្នុងករណីដែលមានស្ថានភាពជាមត៌កអវិភាគ គេមិនអាចទាមទារឱ្យចែកវត្ថុអវិភាគបានទេ ហើយដើម្បីលុបបំបាត់នូវស្ថានភាពអវិភាគនេះ ត្រូវ “ចែកមត៌ក” (មាត្រា1266)

# 1. ការចែកមត៌ក

- ការចែកមត៌ក(ពីមាត្រា1266ទៅ)
  - ចាំបាច់ត្រូវចាំឱ្យពេលវេលា១ខែកន្លងផុតទៅ ក្រោយពេលចាប់ផ្តើមសន្តតិកម្ម
  - មូលដ្ឋាននៃការបែងចែក(មាត្រា1267)
  - សិទ្ធិអាទិភាពរបស់សហាព័ទ្ធ(មាត្រា1268)
  - អានុភាព:មានអានុភាពប្រតិសកម្ម គិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម(មាត្រា1273)
  - សន្តតិជនអាចយកមត៌កពិសេស មកធ្វើជាកម្មសិទ្ធិតែឯង ឬជាសហកម្មសិទ្ធិក៏បាន។
    - ក្នុងករណីដែលជាសហកម្មសិទ្ធិ ដើម្បីលុបបំបាត់ចោលនូវស្ថានភាពនេះ ត្រូវទាមទារឱ្យចែកវត្ថុអវិភាគ(មាត្រា211)។

# 1. ការចែកមត៌ក

- វិធីចែកមត៌ក
  - ការពិភាក្សាបែងចែកមត៌ក(មាត្រា1266)
  - ការបែងចែកមត៌កដោយតុលាការ(មាត្រា 1270)
    - ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង តារាងឧបសម្ព័ន្ធ 5-17

# 1. ការចែកមត៌ក

- ក្នុងករណីដែលមានមតកសាសន៍ចំពោះសន្តតិជន
  - សន្មតថា មានការកំណត់នូវវិធីបែងចែកមត៌ក ឬមានការកំណត់នូវចំណែកសន្តតិកម្ម (មាត្រា1185)។
  - ហេតុនេះហើយ ពីពេលដែលមតកជនទទួលមរណភាព មត៌កដែលត្រូវបានកំណត់នោះ នឹងធ្លាក់ទៅលើសន្តតិជននោះដោយស្វ័យប្រវត្តិ (មាត្រា1195)។
- ➢មានន័យថា ចំពោះមត៌កដែលត្រូវបាកកំណត់ឱ្យទៅសន្តតិជនណាម្នាក់តាមរយៈមតក៏សាសន៍ គេមិនអាចចែកមត៌កបានទៀតឡើយ។
- ➢បន្ទាប់មក បញ្ហាគឺ ការទាមទារឱ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។

# 1. ការចែកមត៌ក

- ក្នុងករណីដែលមានមតកសាសន៍ចំពោះអ្នកផ្សេងពីសន្តតិជន
  - អច្ច័យទាន (មាត្រា1184, មាត្រា1199)
  - ទ្រព្យសម្បត្តិដែលត្រូវបានធ្វើអច្ច័យទាន មិនអាចយកមកធ្វើជាកម្មវត្ថុនៃការចែកមត៌កបានទេ។

➢បន្ទាប់មក បញ្ហាគឺ ការទាមទារឱ្យគាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។

# 2. ពាក្យសុំឱ្យចែកមត៌ក

- ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ តើមានអ្វីខ្លះ ?
  - ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង មាត្រា26
  - ដីកាសម្រេចដែលទាមទារ
  - អង្គហេតុដែលជាមូលហេតុ

# 3. ដីកាសម្រេចដែលទាមទារ

- អ្វីទៅ ដីកាសម្រេចដែលទាមទារ ?
  - "ទាមទារដីកាសម្រេចចែកមត៌ករបស់មតកជន"។
  - អាចសរសេរលំអិតអំពីវិធីចែកដែលទាមទារក៏បានដែរ។

# 4. អង្គហេតុដែលជាមូលហេតុ

- អង្គហេតុដែលជាមូលហេតុ គឺអ្វីទៅ ?
  - មរណភាពរបស់មតកជន
  - ១ខែបានកន្លងផុតទៅ
  - អ្នកដាក់ពាក្យ គឺទាល់តែជាសន្តតិជន
  - ភាគីម្ខាងទៀត គឺសន្តតិជនទាំងអស់គ្នា
  - ត្រូវតែជាមត៌កដែលត្រូវចែក(មានមតកសាសន៍ ឬគ្មាន, ខ្លឹមសារនៃមត៌កសាសន៍, ទំហំនៃមត៌ក)
  - ក្នុងករណីដែលការពិភាក្សារវាងសហសន្តតិជនស្តីពីបែងចែកមត៌ក ពុំបានសម្រេច ឬ ក្នុងករណីដែលពុំអាចពិភាក្សាបាន(មាត្រា1270)

# 5. ចំណុចដែលត្រូវសរសេរក្រៅពីនេះ

- ក្រៅពីនេះ  តើត្រូវសរសេរអ្វីខ្លះទៀត នៅក្នុងពាក្យសុំ ?
- ស្តីពីការបែងចែក  សូមពិចារណាថា តើតុលាការត្រូវធ្វើការវិនិច្ឆ័យដោយផ្អែកលើសភាពការណ៍អ្វីខ្លះ ?
- តុលាការអាចយកអង្គហេតុដែលភាគីមិនបានអះអាងមកពិចារណាបាន(ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ, ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង មាត្រា27)
  - ក៏ប៉ុន្តែ  ភាគីគប្បីតែធ្វើការអះអាង ជាការល្អ។

# 5. ចំណុចដែលត្រូវសរសេរក្រៅពីនេះ

កត្តាដែលត្រូវពិចារណា

- ប្រភេទនិងលក្ខណៈពិសេសនៃមត៌ក, ស្ថានភាពនៃជីវភាពរស់នៅរបស់សន្តតិជន ជាដើម (មាត្រា1267)
- មានកាតព្វកិច្ចដែលត្រូវធ្វើសន្តតិកម្មឬទេ(មាត្រា1269)
- ទំនៀមទម្លាប់ ឬ មតិលើសពាក់កណ្តាល(មាត្រា1270 កថាខ័ណ្ឌទី2)
- មានផលប្រយោជន៍ពិសេសឬទេ(មាត្រា1163)
- មានភាគនៃវិភាគទានឬទេ(មាត្រា1166)

- ជាគោលការណ៍ ត្រូវធ្វើការវាយតម្លៃមត៌កទាំងអស់ជាប្រាក់ ហើយបន្ទាប់មក ត្រូវកែតម្រូវទៅតាមផលប្រយោជន៍ពិសេស ភាគនៃវិភាគទាន ហើយធ្វើការបែងចែកទៅតាមចំណែកមត៌ក
- ពេលកំណត់នូវទ្រព្យសម្បត្តិដែលធ្វើលទ្ធកម្មជាក់ស្តែង ត្រូវពិចារណាអំពីស្ថានភាពរស់នៅ ឬទំនៀមទម្លាប់ ឬមតិលើសពាក់កណ្តាល ជាដើម។

# 5. ចំណុចដែលត្រូវសរសេរក្រៅពីនេះ

- វិធីធ្វើសេចក្ដីសម្រេចទៅតាមដំណាក់កាល (ឧទាហរណ៍របស់ជប៉ុន)
  1. វិសាលភាពនៃសន្ដតិជន
  2. ទំហំមត៌ក
  3. ការវាយតម្លៃមត៌ក
  4. ផលប្រយោជន៍ពិសេស, ភាគនៃវិភាគទាន
  5. វិធីបែងចែក
- គឺជាវិធីធ្វើការវិនិច្ឆ័យដោយរៀបចំចំណុចវិវាទតាមរយៈការបញ្ជាក់ទៅតាមលំដាប់លំដោយនីមួយៗនេះថា តើមានវិវាទឬទេ?

# 5–1 វិសាលភាពនៃសន្តតិជន

- តាមធម្មតា គ្មានបញ្ហាទេ
- ករណីដែលមានបញ្ហា
  - ករណីអសុពលភាពនៃអាពាហ៍ពិពាហ៍ ឬអសុពលភាពនៃការសុំកូន ឬករណីដែលទំនាក់ទំនងឪពុកម្ដាយនិងកូន មានវិវាទ
  - ករណីដែលមានវិវាទអំពីអានុភាពនៃមតកសាសន៍

# 5−2 ទំហំមត៌ក

ទំហំមត៌ក

- គោលការណ៍:បានត្រឹមតែទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ហើយក៏មានអត្ថិភាពនៅពេលបច្ចុប្បន្ននេះដែរ។
- ករណីពិសេស:មាត្រា1272
- ក្នុងករណីដែលទ្រព្យសម្បត្តិណាមួយដែលមាននៅពេលចាប់ផ្តើមសន្តតិកម្ម តែសន្តតិជនណាម្នាក់បានគៃបន្លំប្រើប្រាស់បាត់ទៅ ហើយគ្មាននៅពេលបច្ចុប្បន្ននេះ សិទ្ធិទាមទារសំណងនៃការខូចខាត គឺជាទ្រព្យសម្បត្តិសន្តតិកម្ម។ (មាត្រា1272)
- ត្រឹមតែទ្រព្យសម្បត្តិសកម្មទេ គ្មានរួមបញ្ចូលនូវទ្រព្យសម្បត្តិអកម្មទេ។

# 5–2 ទំហំមត៌ក

វត្ថុដែលមានរាប់ជាមត៌ក

- អចលនវត្ថុ, ចលនវត្ថុ
- សាច់ប្រាក់(ឧទាហរណ៍របស់ជប៉ុន)
- សិទ្ធិលើបំណុលអវិភាគ(សិទ្ធិលើការជួល ជាដើម)
- ថ្លៃឈ្នួល ការប្រាក់ក្រោយពេលចាប់ផ្តើមសន្តតិកម្ម(មាត្រា 1272)

វត្ថុដែលមិនរាប់ជាមត៌ក

- សិទ្ធិលើបំណុលដែលអាចចែកបាន
  - ត្រូវតែបែងចែក។ ក៏ប៉ុន្តែប្រសិនជាការព្រមព្រៀងរវាងសន្តតិជនទាំងអស់គ្នា គេអាចចាត់ទុកជាកម្មវត្ថុនៃការបែងចែកមត៌កដែរ។
- វត្ថុសម្រាប់ជំនឿសាសនា និង ចេតិយ(មាត្រា1147 កថាខ័ណ្ឌទី2)
- ប្រាក់ធានារ៉ាប់រងជីវិត គឺជាសិទ្ធិពិសេសរបស់អ្នកទទួលប្រាក់ធានារ៉ាប់រងនោះ(ឧទាហរណ៍របស់ជប៉ុន)

# 5–2 ទំហំមតិក

## ករណីដែលបានតែបន្លំប្រើប្រាស់បាត់ទៅ តើយ៉ាងណាដែរ ?

- ការតែបន្លំប្រើប្រាស់មុនពេលចាប់ផ្តើមសន្តតិកម្ម
  - ➢ មតកជនធ្វើលទ្ធកម្មនូវសិទ្ធិទាមទារឱ្យសងនូវសេចក្តីចម្រើនឥតហេតុ ឬសិទ្ធិទាមទារសំណងនៃការខូចខាតដោយផ្អែកលើអំពើអនីត្យានុកូល។
  - ➢ គឺជាទ្រព្យសម្បត្តិសន្តតិកម្ម ហើយជាសិទ្ធិលើបំណុលដែលអាចបែងចែកបាន ដូច្នេះ ត្រូវតែបែងចែក។
- ការតែបន្លំប្រើប្រាស់ក្រោយពេលចាប់ផ្តើមសន្តតិកម្ម
  - ➢ យោងតាមមាត្រា1272 សិទ្ធិទាមទារឱ្យសងសេចក្តីចម្រើនឥតហេតុ ឬសិទ្ធិទាមទារសំណងនៃការខូចខាត គឺជាទ្រព្យសម្បត្តិសន្តតិកម្ម។
  - ➢ នេះគឺជាសិទ្ធិលើបំណុលដែលអាចបែងចែកបាន ដូច្នេះត្រូវតែបែងចែក។

# 5–3 ការវាយតម្លៃមតិក

វិធីវាយតម្លៃ

- ក្នុងករណីដែលមានការព្រមព្រៀងរវាងភាគីត្រូវគោរពតាមឆន្ទៈរបស់គេ ជាការល្អ លើកលែងតែក្នុងករណីដែលមានបញ្ហា។
- ក្នុងករណីដែលពុំមានការព្រមព្រៀងទេ ត្រូវធ្វើការវិនិច្ឆ័យដោយផ្អែកលើកោសលវិច័យ ឬឯកសារដទៃទៀត។

# 5–4 ផលប្រយោជន៍ពិសេស

- ត្រូវកែតម្រូវចំណែកមត៌ក ទៅតាមបញ្ញត្តិច្បាប់។
- “ប្រទានកម្មដើម្បីជាមូលធននៃជីវភាពរស់នៅ” (មាត្រា1163)
  - ប្រទានកម្មនូវចំណាយលើការសិក្សា ឬចំណាយសម្រាប់ការរស់នៅ
  - ប្រទានកម្មអចលនវត្ថុសម្រាប់ជាលំនៅដ្ឋាន
  - ប្រទានកម្មដីស្រែចំពោះអ្នកស្រែ ជាដើម

# 5—4 ភាគនៃវិភាគទាន

- ចាំបាច់មានពាក្យសុំស្តីពីភាគនៃវិភាគទាន (មាត្រា1166 កថាខ័ណ្ឌទី2)
- ល័ក្ខខ័ណ្ឌបង្កើត

1. មានអំពើដែលជាវិភាគទាន
2. ត្រូវជា "វិភាគទានពិសេស"
3. រក្សា ឬបង្កើនទ្រព្យសម្បត្តិរបស់មតកជន
4. 2 និង 3 មានទំនាក់ទំនងហេតុនិងផល

# 5–5 វិធីបែងចែក

- បែងចែកដាក់ស្នែងនូវមត៌កនីមួយៗ ទៅតាមចំណែកសន្តតិកម្មរបស់សន្តតិជនម្នាក់ៗ។
- ស្តង់ដារ(មាត្រា1267, មាត្រា1268)

# 5—5 វិធីបែងចែក

- វិធីបែងចែក(សូមយោងមាត្រា212)

1. ការបែងចែកវត្ថុដែលមានជាក់ស្តែង
   - ដើម្បីបែងចែកដី ត្រូវវាស់
2. ការបែងចែកដោយមានតម្លៃថ្នូរ(មាត្រា1267 កថាខ័ណ្ឌទី2)
   - ត្រូវមានសមត្ថភាពបង់
3. ការបែងចែកដោយប្តូរជាប្រាក់(មាត្រា1271)
4. ការបែងចែកជាសហកម្មសិទ្ធិ
   - ដោយសារតែនៅសល់ស្ថានភាពអវិភាគ ដូច្នេះមិនល្អទេ។ គេជ្រើសរើសយកវិធីបែងចែកនេះ តែក្នុងករណីដែលមានក្រុមដែលមានផលប្រយោជន៍រួម ឬក្នុងករណីដែលពុំមានវិធីផ្សេងទៀតក្រៅពីនេះ។

# 6. សង្ខេប

នៅក្នុងពាក្យសុំ តើត្រូវសរសេរអ្វីខ្លះ ?

1. ព័ត៌មានមូលដ្ឋាន
   - ឈ្មោះមតកជន, ថ្ងៃខែឆ្នាំដែលបានទទួលមរណភាព ជាដើម
   - ឈ្មោះ អាស័យដ្ឋាន ថ្ងៃកំណើត ជាដើម របស់សន្តតិជន
   - តើបានជជែកអំពីការបែងចែកមត៌កឬទេ ហើយខ្លឹមសារនោះ
     - ជាពិសេស មូលហេតុដែលធ្វើឱ្យការជជែកនោះមិនបានលទ្ធផល (ចំណុចវិវាទដែលអាចមាន)
   - តើមានមតកសាសន៍ឬទេ ហើយខ្លឹមសារនោះ?
   - តើមានបំណុលឬទេ និង ទឹកប្រាក់?
   - តើមានការបែងចែកមត៌កមួយភាគដែរឬទេ ?

# 6. សង្ខេប

2. វិសាលភាពនៃសន្តតិជន
   - រូបបង្ហាញអំពីទំនាក់ទំនងនឹងសន្តតិកម្ម, ប្រសិនជាមានសរសេរអំពីចំណែកមត៌ក កាន់តែប្រសើរ។
3. ទំហំនៃមត៌ក, ទឹកប្រាក់ដែលបានវាយតម្លៃ
   - គប្បីតែមានភ្ជាប់នូវបញ្ជីមត៌ក(តារាង)ជាការល្អ។
   - បើសិនជាអចនវត្ថុ ត្រូវសរសេរអំពីទីតាំង, ទំហំដី, តម្លៃនៃការវាយតម្លៃ, ឈ្មោះកម្មសិទ្ធិករក្នុងបញ្ជីចុះបញ្ជី, ស្ថានភាពបច្ចុប្បន្ន, អ្នកថែរក្សា។
   - ស្តីពីប្រាក់បញ្ញើវិញ ត្រូវសរសេរឈ្មោះធនាគារ, ទឹកប្រាក់, អ្នកថែរក្សា។

# 6. សង្ខេប

4. ផលប្រយោជន៍ពិសេស, ភាគនៃវិភាគទាន
   - គប្បីបង្កើតតារាងដោយមានសរសេរឱ្យច្បាស់លាស់អំពីស្ថានភាពផ្សេងៗ។
5. វិធីបែងចែក
   - សរសេរអំពីគំនិតរបស់ខ្លួន ស្តីពីលទ្ធកម្ម ព្រមទាំងមូលហេតុនោះ។
   - សរសេរអំពីសភាពការណ៍ពាក់ព័ន្ធនឹងបទដ្ឋានក្នុងការបែងចែកនៃមាត្រា1267។